01241324

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 05 / 2016
ម៉ោង (Time/Heure): 14:08
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E29/486/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៦

ជូនចំពោះ៖ ភាគីទាំងអស់នៃសំណុំរឿង ០០២

ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

កម្មវត្ថុ៖ សេចក្តីសម្រេចលើសាក្សី 2-TCW-812

១. អង្គជំនុំជម្រះសាលាដំបូង បានសម្រេចជ្រើសរើសសាក្សីដែលមានរហស្សនាម 2-TCW-812 មកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធទៅនឹងអង្គហេតុនៃការបោសសម្អាតផ្ទៃក្នុង។ អង្គជំនុំជម្រះមិនអាចធានាវត្តមានសាក្សី 2-TCW-812 នៅចំពោះមុខ អ.វ.ត.ក បានឡើយ ហេតុនេះ អង្គជំនុំជម្រះសូមជូនដំណឹងភាគីទាំងអស់អំពីសេចក្តីសម្រេចរបស់ខ្លួនក្នុងការឈប់ព្យាយាមកោះហៅបុគ្គលនេះតទៅទៀត។

២. នៅថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤ មេធាវីការពារក្តី នួន ជា បានស្នើថា សាក្សី 2-TCW-812 គួរមកផ្តល់សក្ខីកម្មអំពីអង្គហេតុមួយចំនួន រួមមាន ការបោសសម្អាតផ្ទៃក្នុង (ឯកសារ E305/04.2 ទំព័រ ១)។ មេធាវីការពារក្តី នួន ជា មិនមានព័ត៌មានលម្អិតដើម្បីទាក់ទងសាក្សីរូបនេះទេ ប៉ុន្តែបានបង្ហាញថា លោក Stephen Heder ប្រហែលជាអាចផ្តល់ព័ត៌មានថែមទៀតអំពីទីលំនៅរបស់សាក្សីរូបនេះ (ឯកសារ E305/4.1ទំព័រ ១)។

៣. នៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានជូនដំណឹងភាគីទាំងអស់ថា អង្គជំនុំ-ជម្រះបានជ្រើសរើសសាក្សី 2-TCW-812 ប៉ុន្តែ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ មិនទាន់អាចរកគាត់ឃើញទេ ហើយអង្គជំនុំជម្រះនឹងជូនដំណឹងភាគីទាំងអស់ នៅពេលដែលមានព័ត៌មានថែមទៀត (អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦)។ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៦ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានដាក់របាយការណ៍ផ្ញើជូនអង្គជំនុំជម្រះ ដោយផ្តល់ព័ត៌មានលម្អិតអំពីការព្យាយាមធ្វើការទាក់ទងសាក្សីរូបនេះដើម្បីចូលមកផ្តល់សក្ខីកម្ម (ឯកសារ E29/486)។ អង្គជំនុំជម្រះកត់សម្គាល់ថា អង្គភាពគាំពារសាក្សី និងអ្នកជំនាញមិនអាចទទួលបានតម្រុយអំពីទីលំនៅរបស់សាក្សីរូបនេះតាមរយៈឯកសារដែលមាននៅក្នុងសំណុំរឿងទេ (ឯកសារ D210/7 និង E3/514)។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានពិគ្រោះយោបល់ជាមួយនឹងបុគ្គលិករបស់ ក.ស.ច.ស ដែលផ្តល់ព័ត៌មានថា សាក្សីរូបនេះទំនងជាស្លាប់បាត់ហើយ ប៉ុន្តែមិនមានភ័ស្តុតាងបញ្ជាក់ទេ។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញក៏បានទាក់ទងលោក Heder ដែលមេធាវីការពារក្តី នួន ជា បានបង្ហាញថាជាអ្នកសម្ភាសន៍សាក្សី 2-TCW-812 (សូមមើលឯកសារ E305/4.1 ទំព័រ ១ និង D210/7)។ តាមរយៈអ៊ីមែល នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ លោក Heder បានជូនដំណឹងមកអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ថាគាត់មិនមានព័ត៌មានលម្អិតដើម្បីទាក់ទងសាក្សីរូបនេះទេ។ លោក Heder បានជូនដំណឹងថែមទៀតថា គាត់ក៏បានឮដែរថា សាក្សី 2-TCW-812 បានស្លាប់ "យូរដែរហើយ" (ឯកសារ E29/486)។

៤. អង្គជំនុំជម្រះយល់ឃើញថា មានការព្យាយាមច្រើនគួរសមហើយដើម្បីទទួលបានព័ត៌មានអំពីសាក្សីរូបនេះ។ អង្គជំនុំជម្រះកត់សម្គាល់ថា ខ្លួនមិនអាចទទួលបានព័ត៌មានដើម្បីបញ្ជាក់អំពីទីលំនៅរបស់សាក្សីរូបនេះ ឬអំពីសុខភាពរបស់គាត់ ឬក៏ថាតើគាត់នៅរស់ ឬក៏ស្លាប់នោះទេ។ ការស៊ើបសួរថែមទៀតក៏មិនទំនងជាអាចផ្តល់ព័ត៌មានលម្អិតថែមទៀតឲ្យបានទាន់ពេលវេលាសមស្របដែរ។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ខ្លួនមិនអាចទទួលបានសក្ខីកម្មពីសាក្សី 2-TCW-812 ឡើយ ហេតុដូចនេះហើយ អង្គជំនុំជម្រះសម្រេចឈប់ព្យាយាមកោះហៅគាត់តទៅទៀត។